**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨៦.០..សសរ.ឆរ.រ..

# សេចក្ដីសំរេច

## ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយទីកន្លែងសំរាប់មជ្ឈមណ្ឌល ឯកសារកម្ពុជា

---

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសភាពការណ៍ចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងដោះស្រាយទីកន្លែងសំរាប់សាងសង់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម | **អ៊ឹក សុជាតិ** | អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៣-ឯកឧត្តម | **រ៉ុន្ត សារិន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | សមាជិក |
| ៤-ឯកឧត្តម | **ប៊ុន សំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម | **ម្សាស់ លាស់** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-ឯកឧត្តម | **ឡេង ម៉េងឡុង** | អគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-ឯកឧត្តម | **ឈួន សុធី** | ទីប្រឹក្សាផ្ទាល់សម្ដេចនាយករដ្ឋមន្ត្រី និងជាប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសុរិយោដីរាជធានីភ្នំពេញ | សមាជិក |
| ៨-លោកឧត្តមសេនីយ៍ត្រី | **ខែត ចរិន្ទ** | នាយកនៃនាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ | សមាជិក |
| ៩-លោក | **សុខ លក្ខិណា** | នាយរងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ | សមាជិក |
| ១០-លោក | **ជ័យ សារឡុង** | អភិបាលខ័ណ្ឌចំការមន | សមាជិក |
| ១១-លោក | **ជ័យ សុតារ៉ា** | ប្រធានសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង | សមាជិក |
| ១២-លោក | **ឆាំង យុ** | នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា | សមាជិក |

**ប្រការ ២ :** គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ច ដូចតទៅ :

-ចុះពិនិត្យដល់ទីកន្លែង

-ស្រាវជ្រាវបញ្ហាជាប់ពាក់ព័ន្ធ និងពិនិត្យសំណូមពររបស់ប្រជាជនដែលរស់នៅទីនោះ ដើម្បីជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេចដោះស្រាយ ។

-រៀបចំចាត់ចែងលិខិតបទដ្ឋានគតិយុត្តិដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

-ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលការងារដែលអនុវត្ត និងសុំយោបល់សំរេចក្នុងករណីចាំបាច់ ។

**ប្រការ ៣ :** សមាជិកគណៈកម្មការអន្តរក្រសួងដោះស្រាយទីកន្លែងសំរាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចប្រការ៥

-ឯកសារ-កាលប្បវត្តិ.

/II.